# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីព្រះមហាក្សត្រខ្មែរថ្មី និងអនាគតនៃប្រទេសកម្ពុជា

**Website: www.hoksavann.org**

ថ្ងៃទី២៨ តុលា ២០០៤

ទុកបញ្ហាការបង្កើតច្បាប់សំរាប់ក្រុមប្រឹក្សារាជសម្បត្តិជ្រើសរើសព្រះមហាក្សត្រ ឲ្យអ្នកច្បាប់វិនិច្ឆ័យថា តើទំរើដែលធ្វើមកហើយខុសច្បាប់ឬត្រូវច្បាប់ ។ ពេលនេះ សូមធ្វើវិភាគតែទៅលើព្រះមហាក្សត្រខ្មែរថ្មី ដែលទើបតែជ្រើសតាំងកន្លងមកហើយនេះ តើអនាគតនៃប្រទេសកម្ពុជានឹងទៅជាយ៉ាងណា ? អំណាចសព្វថ្ងៃនេះ ស្ថិតនៅលើកណ្តាប់ដៃនៃគណបក្សប្រជាជនកម្ពុជា ឯគណបក្សហ៊្វុនស៊ិនប៉ិចគ្មានឥទ្ធិពលអ្វីឡើយ គ្រាន់តែជារណបរបស់គណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ ។ ភស្តុតាងគ្រាន់តែប្រមុខដឹកនាំបែរាជរដ្ឋាភិបាលខ្មែរ ប្រកាសថាត្រូវធ្វើច្បាប់និងជ្រើសរើសព្រះមហាក្សត្រថ្មី ឲ្យបានសំរេចក្នុងរយៈពេលមួយអាទិត្យ ក៏បានសំរេចដូចបំណង ។ ដូច្នេះបញ្ជាក់ថា អ្វីដែលគណបក្សប្រជាជនមានបំណងធ្វើ តែងតែបានសំរេច ឬបានសំរេចដោយយឺតយូរ ដូចច្បាប់កាត់ទោសខ្មែរក្រហម ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ការបង្កើតក្រសួងអន្តោប្រវេសន៍ជាដើម ។ ឯគណបក្សហ៊្វុនស៊ិនប៉ិចឃើញតែពូកែប្តឹងផ្តល់គណបក្សសម-រង្ស៊ី តែជាអតីតសម្ព័ន្ធមិត្តរបស់ខ្លួនទៅវិញ ។ ក្រុមមនុស្សដែលពុំមែនជាកុម្មុយនិស្ត តែចោទពួកកុម្មុយនិស្តថាជារបបផ្តាច់ការ ពុំគោរពសិទ្ធិមនុស្ស និងពុំមានប្រជាធិបតេយ្យ ឯពួកកុម្មុយនិស្តវិញតែងចោទក្រុមស្តេចនិងបក្សពួកស្តេច ថាជាពួកសក្តិភូមិជិះជាន់ឲ្យគេលុតក្រាប ។ បែរមកមើលបច្ចុប្បន្នភាពនេះវិញ បន្ទាប់ពីក្រុមប្រឹក្សារាជសម្បត្តិបានជ្រើសរើសព្រះមហាក្សត្រថ្មីរួចហើយ មិនទាន់ទាំងបានអភិសេកឲ្យសោយរាជ្យតាមលក្ខណៈច្បាប់ផង ស្រាប់តែប្រមុខរាជរដ្ឋាភិបាល ប្រធានព្រឹទ្ធសភា និងពួកអាជ្ញាធរខ្មែរដទៃទៀត ដែលសុទ្ធតែជាបក្សជននៃគណបក្សប្រជាជនកម្ពុជា បានសរសេរលិខិតជាបន្តបន្ទាប់គ្នាកោតសរសើរព្រះមហាក្សត្រថ្មី ដែលជ្រើសតាំងពុំទាន់ឃើញស្នាព្រះហស្តផង សុខចិត្តក្រាបក្រោមល្អងធូលីព្រះបាទ ជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋខ្មែរជាកូនចៅ ទន្ទឹមគ្នានឹងគណបក្សហ៊្វុនស៊ិនប៉ិច ដែលជាគណបក្សរាជានិយម បែរជាស្ងាត់ឈឹង ពុំសរសេរលិខិតលើកសរសើរព្រះមហាក្សត្រថ្មីនឹងគេសោះ ឯគណបក្សសម-រង្ស៊ីជាគណបក្សប្រឆាំងដែលធ្លាប់និយាយសរសើរព្រះមហាក្សត្រក៏ស្ងាត់ឈឹងដែរ ។ សកម្មភាពរបស់គណបក្សប្រជាជនបែបនេះមានន័យជ្រៅណាស់ គណបក្សប្រជាជនមានបញ្ញាឆ្លាតណាស់ ដោយគេមើលឃើញថា របបរាជានិយមនៅតែមានរាស្ត្រស្រុកស្រែចំការ ដ៏ច្រើនលើសលប់ស្រឡាញ់និងគាំទ្រ ដូច្នេះគេត្រូវតែសម្របសម្រួលបែបនេះជាបណ្តោះអាសន្ន ដើម្បីឲ្យមានស្ថេរភាពខាងនយោបាយ ។ មួយទៀតគេចង់ទាញយកប្រយោជន៍ពីព្រះមហាក្សត្រថ្មី ដូចសុភាសិតខ្មែរបូរាណពោលថា ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់ ។ សម្លាប់អាចារ្យ គឺសម្លាប់ចិត្តអាចារ្យ ឲ្យខ្ជាក់ចំណេះវិជ្ជាដល់ខ្លួន ដោយវិធីបំរើផ្គាប់គុណាឲ្យអាចារ្យពេញចិត្ត ។ យ៉ាងណាមិញ ថោកអ្វីនឹងដៃថ្លៃអ្វីនឹងមាត់ បើចេះកោតសរសើរគោរពប្រណិប័តន៍ទៅ ព្រះមហាក្សត្រនឹងសព្វព្រះទ័យ ថ្ងៃក្រោយបើរាជរដ្ឋាភិបាលត្រូវការពឹងពាក់ព្រះមហាក្សត្រ ឬសុំថ្វាយឲ្យចុះព្រះហស្តលេខាលើក្រឹត្យក្រមអ្វីមួយ ដើម្បីយកទៅប្រើឲ្យស្របច្បាប់ ព្រះមហាក្សត្រពុំហ៊ានប្រកែកទេ ទោះបីកន្លែងខ្លះប្រះអង្គមិនសព្វព្រះទ័យក៏ដោយ ។

ចំណែកព្រះមហាក្សត្រថ្មី ទោះបីព្រះអង្គមិនទាន់មានការពិសោធន៍ក្នុងតំណែងដ៏ខ្ពង់ខ្ពស់ជាព្រះមហាក្សត្រ ប៉ុន្តែមានព្រះអតីតព្រះមហាក្សត្រជាព្រះបិតាជួយពន្យល់ណែនាំក្នុងមុខតំណែងដ៏ខ្ពង់ខ្ពស់នេះ។ តើព្រះមហាក្សត្រថ្មីដើរតាមព្រះមាគ៌ាព្រះបិតា១០០% ឬត្រឹមកំរឹតណា ។ ព្រះអតីតព្រះមហាក្សត្រខ្មែរធ្លាប់បានការពារបូរណភាពទឹកដីខ្មែរមិនឲ្យបាត់បង់ម ក្នុងអំឡុងឆ្នាំ១៩៦០ ព្រះអង្គបានប្រកាសអំពាវនាវឲ្យអន្តរជាតិ ជាពិសេសប្រទេសជិតខាង ឲ្យទទួលស្គាល់បូរណភាពទឹកដីខ្មែរ ។ តើព្រះមហាក្សត្រថ្មីមានព្រះបំណងបំពេញកិច្ចខ្លះដែលព្រះបិតាពុំទាន់បានបំពេញ ដូចជាការធ្វើអនុសាសន៍ឲ្យរាជរដ្ឋាភិបាលលុបចោល នូវសន្ធិសញ្ញាខុសច្បាប់អំឡុងឆ្នាំ១៩៧៩និងអំឡុងឆ្នាំ១៩៨០ ដែលរដ្ឋាភិបាលរដ្ឋកម្ពុជាចុះសន្ធិសញ្ញាជាមួយវៀតណាម អំពីបញ្ហាទឹកដីរវាងប្រទេសទាំងពីរជាដើម ។ ពិតមែនតែព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចតាមមាត្រា៧ក៏ដោយ ប៉ុន្តែព្រះអង្គមានសិទ្ធិមួយជាចាំបាច់ គឺព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការពារសិទ្ធិសញ្ញាអន្តរជាតិតាមមាត្រា៨ ។ ត្រង់មាត្រានេះ ព្រះអង្គមានសិទ្ធិការពារបូរណភាពទឹកដី តាមដានមើលរាជរដ្ឋាភិបាល ក្រែងធ្វើឲ្យបាត់បង់ទឹកដី ។ មួយទៀត បើរាជរដ្ឋាភិបាលបំបិទសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រះអង្គមានសិទ្ធិធ្វើអន្តរាគមន៍បំបាត់ការរំលោភនោះ ។ មាត្រា២៣ចែងថា ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ តើព្រះអង្គមានបំណងយកមាត្រានេះមកប្រើឬទេ ។ សរុបសេចក្តី គណបក្សដែលកាន់អំណាចកុំសរសើរព្រះមហាក្សត្រ ដើម្បីប្រយោជន៍តែបំរើគណបក្សរបស់ខ្លួនឡើយ។ ចំណែកព្រះមហាក្សត្រគប្បីឈរជាកណ្តាល ដើម្បីប្រយោជន៍ជាតិទាំងមូល សេចក្តីទុក្ខរបស់ប្រជារាស្ត្រ គឺជាសេចក្តីទុក្ខរបស់ព្រះអង្គ តាមព្រះរាជបន្ទូលរបស់ព្រះបាទជ័យវរ្ម័នទី៧ ។៚